ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខ: ១៦៧ MISTI / ២០២២

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ក្រមសីលធម៌ស្រាវជ្រាវ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១០៧៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញសេចក្តីសម្រេចលេខ ១០៦ សសរ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងកិច្ចប្រជុំលើកទី២ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២២
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

### ប្រការ១._

ត្រូវបានដាក់ឱ្យប្រើប្រាស់ក្រមសីលធម៌ស្រាវជ្រាវសម្រាប់រូបវន្តបុគ្គល និងនីតិបុគ្គល ដែលធ្វើការស្រាវជ្រាវទាក់ទងនឹងសង្គម និងវិទ្យាសាស្ត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមព្រះរាជក្រឹត្យលេខ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

នស/រកត/១០២០/១០៧៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ២.-**

ក្រមសីលធម៌ស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មាននៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣ កើត ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០២២

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
**និងជាប្រធានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

***កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ***

**កន្លែងទទួល៖**
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមសីលធម៌ស្រាវជ្រាវ

ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

២០២២

# សេចក្តីថ្លែងអំណរគុណ

ក្រុមសីលធម៌ស្រាវជ្រាវនេះ ជាភស្តុតាងនៃគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់ប្រកបដោយទស្សនៈវិស័យរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងនាមជាប្រធានក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក.ជ.វ.ប.ន.)។ ក្រុមការងារលេខាធិការដ្ឋាន ក.ជ.វ.ប.ន. សូមថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅបំផុតដល់សុធន្នៈដ៏ឧត្តុង្គឧត្តមនេះ។ ជាងនេះទៅទៀត ការរួមចំណែកជាអនុសាសន៍ដែលពោរពេញដោយអត្ថន័យ និងខ្លឹមសាររបស់គណៈប្រឹក្សាយោបល់របស់ ក.ជ.វ.ប.ន. ជាគុណប្រយោជន៍ដ៏មានសារៈសំខាន់បំផុតក្នុងការរៀបរៀងបង្កើតឯកសារជាតិនេះឡើង។ សេចក្តីថ្លែងអំណរគុណសូមជូនផងដែរដល់ក្រុមការងារលេខាធិការដ្ឋាន ក.ជ.វ.ប.ន. ដែលបានស្រាវជ្រាវ រៀបចំ ចងក្រង ប្រមូលធាតុចូល និងសំយោគនូវព័ត៌មាន ចំណេះដឹង និងធាតុចូលផ្សេងៗ។ ឯកសារជាតិដ៏មានតម្លៃនេះនឹងមិនអាចសម្រេចចេញជារូបភាពបានឡើយ បើមិនមានក្រុមការងារដ៏សកម្មនេះ។

ក្រុមការងារសូមឧទ្ទិសនូវអំណរគុណជាអនេកប្បការដល់ស្ថាប័នទាំងអស់របស់ ក.ជ.វ.ប.ន. ដែលបានផ្តល់ធាតុចូលជាលាយលក្ខណ៍អក្សរ និងបញ្ជូនមន្ត្រីបច្ចេកទេសដើម្បីផ្តល់អនុសាសន៍បន្ថែមក្នុងសិក្ខាសាលាពិគ្រោះយោបល់លើឯកសារនេះ។ ធាតុចូលទាំងឡាយនោះមានជួយជាពន្លឺកដល់ក្រុមការងារក្នុងការសម្រួចនិងសម្រួលឯកសារជាតិនេះឱ្យកាន់តែមានតម្លៃ គ្រប់ជ្រុងជ្រោយ និងបរិយាប័ន្ន។ សេចក្តីថ្លែងអំណរគុណសូមជូនផងដែរដល់អ្នកស្រាវជ្រាវជាតិ និងអន្តរជាតិតាមរយៈការពិគ្រោះយោបល់ដាច់ដោយឡែក ចំពោះការចែករំលែកនូវឧត្តមគំនិត និងបទពិសោធន៍ ស្តីពីក្រុមសីលធម៌ស្រាវជ្រាវដែលជាគំរូម៉ូដែលផ្សេងៗ។

ជាចុងបញ្ចប់ ក្រុមសីលធម៌ស្រាវជ្រាវនេះអាចបដិសន្ធិឡើងបានតាមរយៈការគាំទ្រជាកម្លាំងចិត្ត ដំណើរការរដ្ឋបាល និងឯកសារច្បាប់ពាក់ព័ន្ធផ្សេងៗពីថ្នាក់ដឹកនាំ និងមន្ត្រីទាំងឡាយរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្រុមការងារសូមវាយតម្លៃខ្ពស់ដល់ការជ្រោមជ្រែងនិងសាមគ្គីភាពនេះ។

## ១. សេចក្តីថ្លែងហេតុ

ការគោរពបានខ្ជាប់ខ្ជួននូវ «ក្រមសីលធម៌ស្រាវជ្រាវ» ជាគុណតម្លៃរបស់បុគ្គលដ៏ខ្ពង់ខ្ពស់ និងមានន័យលើសពីសុជីវធម៌ សីលធម៌ គុណធម៌ និងបទប្បញ្ញត្តិនៃច្បាប់។ ក្រមនេះសំដៅដល់សេចក្តីទូន្មានជាប្រចាំសម្រាប់ការស្រាវជ្រាវ ក្នុងរូបភាពជាបណ្តុំនៃបទដ្ឋាន គុណតម្លៃ និងបែបផែនតាមស្ថាប័នដែលរួមចំណែកដល់ការបង្កើត និងនិយតកម្មសកម្មភាពស្រាវជ្រាវ ទាំងនេះរួមមានកាតព្វកិច្ចនៃភាពស្មោះត្រង់ក្នុងការស្រាវជ្រាវ និងការចូលរួមទទួលខុសត្រូវចំពោះសហការី អ្នកដទៃ សត្វ បរិស្ថាន និងសង្គមជាទូទៅលើសកម្មភាព និងលទ្ធផលនៃការស្រាវជ្រាវ។ តម្លៃ និងអត្ថប្រយោជន៍នៃកិច្ចការស្រាវជ្រាវផ្តោតសំខាន់លើសុចរិតភាព។ សុចរិតភាពជាគុណតម្លៃនៃភាពខ្ពង់ខ្ពស់ និងការលើកតម្កើងភាពជឿនលឿនរបស់មនុស្ស។ ដូច្នេះការប្រកាន់ខ្ជាប់នូវ «ក្រមសីលធម៌ស្រាវជ្រាវ» គឺជាមូលដ្ឋានគ្រឹះនៃការស្រាវជ្រាវដ៏សំខាន់ដើម្បីធានាឱ្យបាននូវកំណើតនៃពុទ្ធិ និងនវានុវត្តន៍ក្នុងគ្រប់វិស័យ។

តម្រូវការក្រមសីលធម៌សម្រាប់អ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ ជារបត់ថ្មីមួយដែលប្រទេសនៅលើសាកលលោកបាននិងកំពុងយកចិត្តទុកដាក់ខ្លាំងក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ដោយហេតុថាកិច្ចការស្រាវជ្រាវមាននៅក្នុងគ្រប់វិស័យរួមទាំងវិស័យឯកជន និងសាធារណៈ។ ចំណេះដឹងថ្មីៗបានបង្កើត និងលេចឡើងយ៉ាងឆាប់រហ័សក្នុងទម្រង់ជាបច្ចេកវិទ្យា និងវិធីសាស្ត្រជាអាទិ៍។ ទោះយ៉ាងនេះក្តី បដិវត្តន៍ឧស្សាហកម្មក៏ត្រូវបានចោទជាសំណួរអំពីផលប៉ះពាល់យ៉ាងខ្លាំងដល់មនុស្សជាតិ និងបរិស្ថានផងដែរ។ ជាក់ស្តែងបច្ចេកវិទ្យាផ្សេងៗដែលបម្រើឱ្យឧស្សាហកម្មជំនាន់ទី៤ អាចជាចំណោទឱ្យមានការពិចារណាកាន់តែខ្លាំងថែមទៀតលើក្រមសីលធម៌នៃការស្រាវជ្រាវ។ កត្តាផ្សេងៗជាអាទិ៍៖ បទដ្ឋានគតិយុត្ត ទំនៀមទម្លាប់ កម្មសិទ្ធិបញ្ញា សិទ្ធិមនុស្ស ឯកជនភាព សុវត្ថិភាពទិន្នន័យ ចីរភាព ស្ថិរភាពសង្គម និងភាពប្រែប្រួលលឿននៃបច្ចេកវិទ្យាបាននិងកំពុងជំរុញឱ្យមាននិយាមពិតប្រាកដ និងជាក់លាក់មួយចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រតិបត្តិការស្រាវជ្រាវ។ ព្រះរាជាណាចក្រកម្ពុជាក៏មិនខុសពីប្រទេសផ្សេងៗទៀតក្នុងសាកលលោកដែរ ត្រូវរៀបចំក្រមសីលធម៌ស្រាវជ្រាវដ៏សមស្របមួយ។ ក្រមសីលធម៌ស្រាវជ្រាវនេះមិនត្រឹមតែជាត្រីវិស័យដល់ការស្រាវជ្រាវប៉ុណ្ណោះទេ ថែមទាំងជាទស្សនាទានដល់រាជរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ផងដែរ ក្នុងការចូលរួមលើកតម្កើងការស្រាវជ្រាវស្របតាមផលប្រយោជន៍ និងសន្តិសុខជាតិប្រកបដោយការទទួលខុសត្រូវ ភាពស្មោះត្រង់ សុចរិតភាព និងគណនេយ្យភាព។

ការវិវត្តនៃការស្រាវជ្រាវទៅតាមតម្រូវការនៃមនុស្ស បាននិងកំពុងជំរុញឱ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំងថែមទៀតលើផលវិបាក និងផលជះជាអវិជ្ជមានពីសមិទ្ធផលនៃការស្រាវជ្រាវដែលរួមបញ្ចូលទាំងការបោះពុម្ពផ្សាយផងដែរ។ ទង្វើផ្សេងៗដែលអាចកើតមានពីការស្រាវជ្រាវអាចផ្តល់ផលអវិជ្ជមានដល់សង្គម រួមមាន៖ ការបកស្រាយទិន្នន័យមិនត្រឹមត្រូវ ការបន្លំទិន្នន័យ ការបំប្លែងទិន្នន័យឬរូបភាព ការបំពានលើឯកជនភាព ការរំលោភសិទ្ធិមនុស្សនិងសត្វ និងការរំលោភលើកម្មសិទ្ធិបញ្ញាជាដើម។ កត្តាទាំងអស់នេះអាចនឹងផ្តល់ផលមិនល្អកាន់តែធ្ងន់ និងលឿនថែមទៀត ពេលដែលប្រព័ន្ធផ្សព្វផ្សាយដ៏សម្បូណ៌បែបដូចសព្វថ្ងៃចែករំលែកនូវព័ត៌មានស្រាវជ្រាវខុសឆ្គងអ្វីមួយដោយចេតនា ឬអចេតនាក្នុងគោលបំណងបម្រើគោលដៅអ្វីមួយ។

ជាទូទៅការគោរពខ្ជាប់ខ្ជួននូវក្រមសីលធម៌នៃការស្រាវជ្រាវ មិនត្រឹមតែបណ្តុះនូវវប្បធម៌សុចរិតភាពប៉ុណ្ណោះទេ ថែមទាំងជួយផ្តល់នូវកិច្ចសហការល្អ និងទុកចិត្តគ្នាដែលជាមូលដ្ឋានគ្រឹះនៃការបង្កើតចំណេះពីការស្រាវជ្រាវ ក្នុងគោលដៅបម្រើឱ្យមនុស្សជាតិ។ ការប្រតិបត្តិបានត្រឹមត្រូវនូវក្រមសីលធម៌ស្រាវជ្រាវ ជាឥរិយាបថដ៏ថ្លៃថ្នូរ ដែលជាតម្រូវការមិនអាចខ្វះបានក្នុងបរិបទសាកលភាវូបនីយកម្ម។ ទង្វើបែបនេះនឹងផ្តល់ជាប្រយោជន៍ដ៏ឧត្តុង្គឧត្តមដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម តាមរយៈការប្រើប្រាស់ចំណេះដឹងថ្មីៗដែលទទួលបានពីការស្រាវជ្រាវ។ ហេតុដូច្នេះ គោលការណ៍និងការទទួលខុសត្រូវវិជ្ជាជីវៈលើការស្រាវជ្រាវ ត្រូវតែរៀបរៀងឡើងជាមូលដ្ឋាននៃសុចរិតភាពដើម្បីធានាឱ្យមានរបៀបស្រាវជ្រាវមួយមានលក្ខណៈទទួលយកបានជាទូទៅ។

ដោយឃើញបញ្ហាប្រឈម កាលានុវត្តភាព និងសារៈសំខាន់នៃការស្រាវជ្រាវប្រកបដោយក្រមសីលធម៌ ការរៀបចំជានិយាមរួមមួយសម្រាប់កិច្ចស្រាវជ្រាវនៅព្រះរាជាណាចក្រកម្ពុជាជាកិច្ចការយ៉ាងសំខាន់មួយ ដើម្បីធានាឱ្យបាននូវឧត្តមានុវត្តជាតិប្រកបដោយចំណេះដឹង និងការទទួលខុសត្រូវខ្ពស់។ ការណ៍នេះនឹងជួយជ្រោមជ្រែងបន្ថែមទៀតដល់សង្គមស្រាវជ្រាវក្នុងប្រទេស ដើម្បីចៀសវាងកំហុសឆ្គងផ្សេងៗក្នុងដំណើរការស្រាវជ្រាវ និងគ្រប់គ្រងការស្រាវជ្រាវ។ អ្នកស្រាវជ្រាវត្រូវប្រកាន់ភ្ជាប់នូវក្រមសីលធម៌របស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន ដើម្បីទទួលបាននូវព័ត៌មាន និងទិន្នន័យប្រកបដោយគុណភាព និងរក្សាបាននូវតម្លៃនៃការស្រាវជ្រាវរបស់ខ្លួន។

## ២. ចក្ខុវិស័យ

ការស្រាវជ្រាវប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈខ្ពស់លើការបង្កើតពុទ្ធិ ដោយឈរលើមូលដ្ឋាននៃការអភិវឌ្ឍសហគមន៍ស្រាវជ្រាវ និងផលប្រយោជន៍និងសន្តិសុខជាតិ ដើម្បីវឌ្ឍនភាពសុខុមាលភាពសេដ្ឋកិច្ច-សង្គម។

## ៣. គោលបំណង

ក្រមសីលធម៌ស្រាវជ្រាវនេះត្រូវបានរៀបចំឡើង ដើម្បីជំរុញឱ្យអ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវអនុវត្តកាតព្វកិច្ចរបស់ខ្លួនប្រកបដោយក្រមសីលធម៌ខ្ពស់ ក្នុងគោលដៅធានាឱ្យបាននូវគុណតម្លៃក្នុងការស្រាវជ្រាវ។ គោលបំណងចម្បងនៃក្រមសីលធម៌ស្រាវជ្រាវគឺ៖

- លើកកម្ពស់ឥរិយាបថល្អ និងសីលធម៌ក្នុងសហគមន៍ និងសង្គម
- លើកកម្ពស់ផ្នត់គំនិតផ្តល់តម្លៃលើផលប្រយោជន៍រួមរបស់សង្គម
- ជំរុញ និងគាំទ្រដល់ការអភិវឌ្ឍការស្រាវជ្រាវប្រកបដោយបរិយាប័ន្ន
- បណ្តុះវប្បធម៌ស្រឡាញ់ការស្រាវជ្រាវ។

## ៤. គោលការណ៍

ជាគោលការណ៍ការស្រាវជ្រាវដែលមានក្រមសីលធម៌ ទាមទារឱ្យមានការពិចារណាឱ្យបានដិតដល់លើអ្នកស្រាវជ្រាវផ្ទាល់ ស្ថាប័នស្រាវជ្រាវ និងផលប៉ះពាល់ផ្សេងៗដល់បរិស្ថាន។ រាល់កិច្ចការស្រាវជ្រាវដែលមានការទាក់ទងផ្ទាល់ជាមួយ មនុស្ស សត្វ ជីវចម្រុះ និង/ឬការប្រមូលទិន្នន័យដែលប៉ះពាល់ជាក់ស្តែងដល់សន្តិសុខ ប្រយោជន៍ និងកិត្តិយសសង្គម ត្រូវមានកិច្ចព្រមព្រៀងជាមុនពីសមត្ថកិច្ចពាក់ព័ន្ធ។

## ៤.១ អ្នកស្រាវជ្រាវ

ការស្រាវជ្រាវគប្បីត្រូវគោរពនូវគោលការណ៍បួនជាមូលដ្ឋានដែលរួមមាន ភាពស្មោះត្រង់ គណនេយ្យភាព សុជីវធម៌វិជ្ជាជីវៈ និងសុចន្ទៈ ដោយឈរលើមូលដ្ឋានបើកចំហ ពង្រឹងសមត្ថភាពជាប្រចាំ និងមានវិជ្ជាជីវៈខ្ពស់។ អ្នកស្រាវជ្រាវត្រូវមានភាពប្រាកដប្រជា ភាពប្រុងប្រយ័ត្នខ្ពស់ និងការទទួលខុសត្រូវលើចំណេះដឹង និងភាពអសកម្មផ្សេងៗដែលមានក្នុងកិច្ចការស្រាវជ្រាវរបស់ខ្លួន។ ជាងនេះទៅទៀត អ្នកស្រាវជ្រាវហាមដាច់ខាតចម្លងស្នាដៃអ្នកដទៃធ្វើជាស្នាដៃរបស់ខ្លួន និងក្លែងបន្លំលទ្ធផលស្រាវជ្រាវ។ បន្ថែមពីលើការគោរពបទដ្ឋានគតិយុត្តរបស់ប្រទេស និងយន្តការរបស់ស្ថាប័ន អ្នកស្រាវជ្រាវត្រូវគោរពនូវសីលធម៌ ប្រពៃណី និងទំនៀមទម្លាប់នៃទីតាំងដែលខ្លួនបានចុះទៅស្រាវជ្រាវ ឬធ្វើបទសម្ភាសន៍ផងដែរ។

### ៤.១.១. ភាពស្មោះត្រង់

ភាពស្មោះត្រង់ត្រូវមានសម្រាប់ការស្រាវជ្រាវទាំងអស់។ អ្នកស្រាវជ្រាវត្រូវទទួលខុសត្រូវ និងរក្សាឱ្យបាននូវភាពស្មោះត្រង់ចំពោះការស្រាវជ្រាវរបស់ខ្លួន។ អ្នកស្រាវជ្រាវត្រូវគោរពឱ្យបានហ្មត់ចត់ទៅតាមបទប្បញ្ញត្តិនៃការស្រាវជ្រាវ និងគោលនយោបាយផ្សេងៗដែលមានការទាក់ទងទៅនឹងការស្រាវជ្រាវ។ អ្នកស្រាវជ្រាវត្រូវធ្វើការវិនិច្ឆ័យ និងសន្និដ្ឋានលើការស្រាវជ្រាវរបស់ខ្លួន ដោយផ្អែកទៅលើទិន្នន័យដែលប្រមូលបាននិងលទ្ធផលវិភាគលក្ខណៈបច្ចេកទេសដែលបានមកវិធីសាស្ត្របែបវិទ្យាសាស្ត្រដែលទទួលស្គាល់ ដោយសហគមន៍ស្រាវជ្រាវរបស់ខ្លួនជាមូលដ្ឋាន។

### ៤.១.២. គណនេយ្យភាព

គណនេយ្យភាពត្រូវមាននៅក្នុងការធ្វើការស្រាវជ្រាវ។ អ្នកស្រាវជ្រាវត្រូវតែរក្សាទុកនូវរាល់ទិន្នន័យឱ្យបានច្បាស់លាស់ កត់ត្រានូវអ្វីដែលពិតប្រាកកដ និងដាក់លាក់នូវគ្រប់ដំណើរការនៃការស្រាវជ្រាវ ដែលអាចឱ្យអ្នកស្រាវជ្រាវដទៃធ្វើការត្រួតពិនិត្យ បញ្ជាក់ និងអាចធ្វើជាឯកសារយោង និងវាយតម្លៃលើកិច្ចការស្រាវជ្រាវ។ អ្នកស្រាវជ្រាវត្រូវតែចែករំលែកឱ្យបានទាន់ពេលនូវលទ្ធផលស្រាវជ្រាវជាចំហ និងទិន្នន័យដែលមិនប៉ះពាល់ដល់សន្តិសុខសេដ្ឋកិច្ច-សង្គម ដើម្បីពង្រីកចំណេះដឹងក្នុងសហគមន៍ ក៏ដូចជារក្សានូវសិទ្ធិជាអាទិភាព និងការអះអាងភាពជាកម្មសិទ្ធិនៃចំណេះដឹងដែលខ្លួនបានបង្កើត។

អ្នកស្រាវជ្រាវត្រូវគោរពឱ្យបាននូវការផ្ដល់យោបល់ប្រកបដោយវិជ្ជាជីវៈខ្ពស់ ក្នុងការទំនាក់ទំនងជាសាធារណៈ ដូចជាសន្និសីទ សិក្ខាសាលា និងព្រឹត្តិការណ៍វិទ្យាសាស្ត្រផ្សេងៗជាដើម ដោយបែងចែកឱ្យបានច្បាស់លាស់នូវយោបល់បែបវិជ្ជាជីវៈក្នុងកិច្ចការស្រាវជ្រាវ និងទស្សនៈផ្ទាល់ខ្លួន។ ជាងនេះទៅទៀតអ្នកស្រាវជ្រាវត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវតម្រូវការចាំបាច់ផ្សេងៗ ក្នុងការរាយការណ៍ទាក់ទងនឹងលទ្ធផលស្រាវជ្រាវ និងថវិកាចំណាយផ្សេងៗផងដែរ។

### ៤.១.៣. សុជីវធម៌វិជ្ជាជីវៈ

អ្នកស្រាវជ្រាវត្រូវប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវឱ្យបានត្រឹមត្រូវ តាមបទដ្ឋានវិទ្យាសាស្ត្រច្បាស់លាស់ ដោយមានឯកសារយោងជាគោលលើវិធីសាស្ត្រនៃការស្រាវជ្រាវរបស់ខ្លួន។ ការធ្វើសេចក្ដីសន្និដ្ឋានត្រូវផ្អែកលើការវិភាគឱ្យបានស៊ីជម្រៅដោយផ្អែកលើភស្តុតាង ហើយរាយការណ៍ពីលទ្ធផលឱ្យបានគ្រប់ជ្រុងជ្រោយទៅតាម

វត្ថុបំណងដែលបានកំណត់។ អ្នកស្រាវជ្រាវត្រូវរក្សានូវសំណៅដើមផ្សេងៗក្នុងពេលស្រាវស្រាវឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ ដើម្បីជាទឡ្ហីករណ៍ក្នុងការផ្ទៀងផ្ទាត់ និងត្រាប់ការស្រាវស្រាវម្តងទៀត ដោយអ្នកស្រាវជ្រាវដទៃទៀត។

អ្នកស្រាវជ្រាវត្រូវទទួលខុសត្រូវលើការរួមចំណែកផ្សេងៗ ក្នុងកិច្ចការស្រាវជ្រាវរបស់ខ្លួនជាអាទិ៍៖ កិច្ចសហការនិង/ឬសហប្រតិបត្តិការ ការបោះពុម្ពផ្សាយ កម្មសិទ្ធិបញ្ញា ការដាក់ស្នើសុំថវិកា របាយការណ៍ និងការចែករំលែកលទ្ធផលក្នុងទម្រង់ផ្សេងៗទៀត។ រាល់ការស្រាវជ្រាវទាំងឡាយត្រូវគោរពឱ្យបាននូវកាតព្វកិច្ចក្រមសីលធម៌ ដោយថ្លឹងថ្លែងឱ្យបានច្បាស់លាស់ពីផលប្រយោជន៍សង្គម និងហានិភ័យជាយថាហេតុក្នុងកិច្ចការស្រាវជ្រាវរបស់ខ្លួន។

បញ្ជីអ្នកនិពន្ធគួររាប់បញ្ចូលអ្នកដែលបានចូលរួមដល់សកម្មភាពស្រាវជ្រាវ។ លំដាប់នៃអ្នកនិពន្ធគួរយោងទៅតាមកម្រិតនៃការចូលរួមបង្កើតចំណេះដឹងរបស់អ្នកនិពន្ធនីមួយៗ។ ជាគោលការណ៍អ្នកនិពន្ធសំដៅដល់អ្នកដែលចូលរួមបង្កើតចំណេះដឹងតាមរយៈការស្រាវជ្រាវ។ សេចក្តីថ្លែងអំណរគុណក្នុងការបោះពុម្ពផ្សាយរបស់អ្នកស្រាវជ្រាវត្រូវរំលេចនូវឈ្មោះ និងតួនាទីបុគ្គល ឬស្ថាប័នដែលបានរួមចំណែកពិតប្រាកដដល់កិច្ចការស្រាវជ្រាវជាអាទិ៍៖ ជំនួយការ ម្ចាស់មូលនិធិ អ្នកជួយឧបត្ថម្ភ ឬអ្នកដទៃផ្សេងទៀត ដែលមិនត្រូវតាមលក្ខណៈវិនិច្ឆ័យជាគោលការណ៍អ្នកនិពន្ធ។

អ្នកស្រាវជ្រាវត្រូវធានាជាដាច់ខាតនូវការវិភាគដោយយុត្តិធម៌ ទាន់ពេលវេលា និងហ្មត់ចត់ និងរក្សាការសម្ងាត់ក្នុងពេលត្រួតពិនិត្យដោយសហវិនិច្ឆយករ។ ក្នុងករណីចាំបាច់ អ្នកស្រាវជ្រាវត្រូវបង្ហាញនូវទំនាស់ផលប្រយោជន៍ហិរញ្ញវត្ថុ និងទំនាស់ផលប្រយោជន៍ផ្សេងទៀត ដើម្បីធានាឱ្យបាននូវភាពជឿជាក់ជាទូទៅលើគម្រោងស្រាវជ្រាវ ការបោះពុម្ពផ្សាយ និងទំនាក់ទំនងសាធារណៈផ្សេងៗ ក៏ដូចជាកិច្ចការពាក់ព័ន្ធនឹងការត្រួតពិនិត្យដោយសហវិនិច្ឆយករ។

### ៤.១.៤. សុចរិតភាព

សុចរិតភាពរបស់អ្នកស្រាវជ្រាវជាគុណតម្លៃគ្រឹះដែលជ្រៅជ្រះ ក្នុងការក្សានូវភាពជឿទុកចិត្តជាសាធារណៈលើការស្រាវជ្រាវ។ អ្នកស្រាវជ្រាវត្រូវតែរាយការណ៍ជូនបុគ្គលមានសមត្ថកិច្ច ចំពោះរាល់សកម្មភាពដែលគ្មានការទទួលខុសត្រូវផ្សេងៗក្នុងការស្រាវជ្រាវ។ សកម្មភាពទាំងនោះរួមមាន ការប្រព្រឹត្តខុសដែលគួរឱ្យសង្ស័យក្នុងការស្រាវជ្រាវជាអាទិ៍៖ ការប្រឌិត ការក្លែងបន្លំ ឬការលួចចម្លងស្នាដៃអ្នកដទៃ និងការអនុវត្តការស្រាវជ្រាវមិនមានលក្ខណៈទទួលខុសត្រូវផ្សេងទៀត ដូចជា ការធ្វេសប្រហែស ការរៀបលំដាប់ឈ្មោះអ្នកនិពន្ធមិនបានត្រឹមត្រូវ ការខកខានមិនបានរាយការណ៍ពីទិន្នន័យដែលគ្មានសង្គតិភាព ឬការប្រើប្រាស់នូវវិធីសាស្ត្រវិភាគមិនត្រឹមត្រូវជាដើម។

## ៤.២. ស្ថាប័នស្រាវជ្រាវ

ស្ថាប័នស្រាវជ្រាវសំដៅដល់នីតិបុគ្គលដែលមានតួនាទី និង/ឬចូលរួមចំណែកដល់ការបង្កើតឱ្យមានចំណេះដឹងថ្មីៗដល់សហគមន៍ស្រាវជ្រាវ។ បរិយាកាសសមប្រកប និងការជ្រោមជ្រែងឱ្យមានភាពស្របច្បាប់សម្រាប់អ្នកស្រាវជ្រាវត្រូវតែបានបង្កើតឡើងក្នុងកម្រិតស្ថាប័ន។ ស្ថាប័នីយកម្មលើការស្រាវជ្រាវសម្រាប់នីតិបុគ្គល

នីមួយៗ គឺជាកត្តាមិនអាចខ្វះបានដើម្បីការបង្កើតចំណេះដឹងប្រកបដោយក្រមសីលធម៌ ស្របតាមផលប្រយោជន៍សង្គម និងសន្តិសុខជាតិ។

### ៤.២.១. ការឆ្លើយតបលើភាពគ្មានការទទួលខុសត្រូវ

ស្ថាប័នស្រាវជ្រាវទាំងឡាយ រួមទាំងគ្រឹះស្ថានបោះពុម្ពផ្សាយជាលក្ខណៈកាលិកបត្រ អង្គការវិជ្ជាជីវៈ និងភ្នាក់ងារដែលមានសកម្មភាពស្រាវជ្រាវ ត្រូវមាននីតិវិធី និងយន្តការ ក្នុងការចោទប្រកាន់លើកំហុសឆ្គង និងការអនុវត្តការស្រាវជ្រាវដោយគ្មានការទទួលខុសត្រូវ និងការដោះស្រាយ។ បន្ថែមពីលើនេះទៅទៀត អង្គភាពត្រូវមាននីតិវិធី និងយន្តការក្នុងស្ថាប័ន ដើម្បីការពារបុគ្គលដែលរាយការណ៍ក្នុងគោលដៅកែលម្អពីទង្វើអវិជ្ជមានទាំងនេះ។ វិធានការទាំងនេះត្រូវកំណត់អំពីការឆ្លើយតបដ៏សមស្របមួយ រួមទាំងការកែតម្រូវលើកំណត់ត្រាស្រាវជ្រាវឱ្យទាន់ពេលវេលា ពេលរកឃើញនូវកំហុសឆ្គង និងការអនុវត្តការស្រាវជ្រាវដែលគ្មានការទទួលខុសត្រូវ។

### ៤.២.២. បរិយាកាសស្រាវជ្រាវ

ជាគោលការណ៍ ការជំរុញនិងបង្កើតឱ្យមានបរិយាកាសល្អពីស្ថាប័នជាកត្តាស្នូលមួយដើម្បីបានការស្រាវជ្រាវមួយប្រកបដោយសុចរិតភាព។ ស្ថាប័នស្រាវជ្រាវត្រូវតែបង្កើត និងរក្សាបរិយាកាសឱ្យបានសមប្រកប ដើម្បីផ្តល់គុណតម្លៃដល់សុចរិតភាព តាមរយៈការអប់រំនិងបណ្តុះបណ្តាលសមត្ថភាពអ្នកស្រាវជ្រាវ គោលនយោបាយច្បាស់លាស់ និងកម្រិតស្តង់ដារសមហេតុផលផ្សេងៗក្នុងគោលដៅជំរុញភាពជឿនលឿន។

### ៤.២.៣. ការទទួលខុសត្រូវលើសង្គម

ស្ថាប័នស្រាវជ្រាវត្រូវគោរពឱ្យបាន និងជំរុញឱ្យមាននូវកាតព្វកិច្ចក្រមសីលធម៌ ដោយថ្លឹងថ្លែងឱ្យបានច្បាស់លាស់ពីផលប្រយោជន៍សង្គម ទល់នឹងហានិភ័យជាយថាហេតុក្នុងសមត្ថកិច្ចការស្រាវជ្រាវរបស់ខ្លួន។

## ៤.៣. បរិស្ថាន

ការស្រាវជ្រាវត្រូវមានការពិចារណាឱ្យបានដិតដល់បំផុត ដល់ផលប៉ះពាល់ដែលអាចកើតមានលើបរិស្ថានរួមរបស់សង្គម។ ជាគោលការណ៍ អ្នកស្រាវជ្រាវ ឬស្ថាប័នស្រាវជ្រាវត្រូវថ្លឹងថ្លែងឱ្យបានច្បាស់លាស់លើសកម្មភាព ក៏ដូចជាលទ្ធផលស្រាវជ្រាវរបស់ខ្លួន និងផលអវិជ្ជមានផ្សេងៗដល់និរន្តរភាពបរិស្ថានធម្មជាតិដែលមានមនុស្ស សត្វ និងរុក្ខជាតិជាអាទិ៍ និងសង្គមមនុស្សទាំងមូល។ ជាឧទាហរណ៍ ការស្រាវជ្រាវដែលទាក់ទងនឹងមនុស្សត្រូវធានាឱ្យបានជាអតិបរមានូវសេចក្តីថ្លៃថ្នូរ ព័ត៌មានសម្ងាត់ ឯកជនភាព សិទ្ធិ សុវត្ថិភាព សុខុមាលភាព និងការព្រមព្រៀងជាមុនលើបុគ្គលដែលត្រូវបានជ្រើសរើសក្នុងការយកសំណាក និង/ឬត្រូវបានសម្ភាសន៍ ជាដើម។ លើសពីនេះទៅទៀត ការស្រាវជ្រាវក្នុងទម្រង់ជាកំណាយបុរាណដ្ឋានផ្សេងៗត្រូវយកចិត្តទុកដាក់ឱ្យបានជាដាច់ខាតនូវតម្លៃប្រវត្តិសាស្ត្រ និងមនុស្សជាតិ។

*ក្រមសីលធម៌នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ប្រធានក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។*